គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CCPCR - CDP - CHHRA - CKIMHRDA - CWCC - GENEROUS - IDA - KKKHRA
KID - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - TASK FORCE - VIGILANCE
Address: No.12, 282, Boeng Keng Kong, Chamcar Mon, P.P, Tel/Fax: 351 415 E-mail: chrac@forum.org.kh

Media Statement

# Trial of H.E. Cheam Channy, SRP Member of Parliament

*Phnom Penh, August 9, 2005*

The Cambodian Human Rights Action Committee (CHRAC), a coalition of 18 local NGOs, closely followed the trial proceedings at the Military Court on August 8th, 2005 to try H.E. Cheam Channy, a member of parliament from the opposition party.

During the hearing, CHRAC observers noted that there was a lack of adequate evidence or credible testimonies to support the charges, of organized crime and committing fraud, against H. E. Cheam Channy by the prosecutor. CHRAC members observed many procedural violations, including the following:

1- This case should not be under the jurisdiction of the military court because, as pointed out by the prosecutor, H.E. Cheam Channy is not a member of the military;
2- During the trial, the defense counsel was not allowed to question all the witnesses of the prosecution, violating Article 24 of the Criminal Law during the Transitional Period and the judge's promise to permit such questioning;
3- The judge did not allow any testimonies from witnesses of the defense, even though H.E. Cheam Channy's lawyer had requested at an earlier stage for his witnesses to be included;
4- There was no credible evidence proving that H.E Cheam Channy had committed these crimes;
5- The judge and prosecutor permitted the court clerk to read statements from witnesses who were either absent or deceased, even though the defense had no opportunity to cross examine them. This is a violation of the rights of the defendant.

CHRAC concludes that there was inadequate evidence to try H.E. Cheam Channy. CHRAC acknowledges it is the judge’s right to sentence or not sentence the accused, but CHRAC strongly calls for the judge to base his decision exclusively on information given during the trial, and not to consider any additional information obtained after the trial.

## Contact Persons

| | | |
|---|---|---|
| **Mr. Sok Sam Oeun** | Chairman of CHRAC and CDP | Tel: 012 901 199 |
| **Dr. Kek Galabru** | President of LICADHO | Tel: 012 803 174 |
| **Mr. Thun Saray** | President of ADHOC | Tel: 016 880 509 |

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CCPCR - CDP - CHHRA - CKIMHRDA - CWCC - GENEROUS - IDA - KKKHRA
KID - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - TASK FORCE - VIGILANCE
Address: No.12, St. 282, Boeng Keng Kong, Chamcar Mon, P.P, Tel/Fax: 351 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

## ស្តីអំពី សវនាការលើករណី ឯកឧត្តម ជាម ច័ន្ទនី

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលរួមមានអង្គការ-សមាគម ក្រៅរដ្ឋាភិបាលចំនួន ១៨ ជាសមាជិក បានធ្វើការតាមដានដោយយកចិត្តទុកដាក់លើដំណើរការនៃការកាត់ក្តីករណី ឯកឧត្តម ជាម ច័ន្ទនី ដោយតុលាការយោធា កាលពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៥។

នៅក្នុងសវនាការ គណៈកម្មាធិការប្រព្រឹត្តិកម្ម បានសង្កេតឃើញថា ការឆ្លើយបំភ្លឺនានារបស់សាក្សីដាក់បន្ទុក និង ការបង្ហាញភស្តុតាង ដើម្បីដាក់បន្ទុកលើឯកឧត្តម ជាម ច័ន្ទនី ពុំមានហេតុផលគ្រប់គ្រាន់សំរាប់ចោទប្រកាន់ទៅលើបទល្មើសទាំងពីរ (ការបង្កើតកងកម្លាំងប្រដាប់អាវុធខុសច្បាប់ និង អំពើឆបោក) ដែលតុលាការយោធាបានធ្វើការចោទប្រកាន់នោះទេ ដោយហេតុថា សវនាការនេះបានប្រព្រឹត្តទៅដោយ ខុសនឹងនីតិវិធីដែលមានដូចខាងក្រោម៖

១-ករណីនេះពុំស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការយោធា ដោយហេតុថា ឯកឧត្តម ជាម ច័ន្ទនី ពុំមែនជាយោធិន ហើយបញ្ហានេះលោកព្រះរាជអាជ្ញាក៏បានទទួលស្គាល់នៅក្នុងសវនាការផងដែរ ។

២-នៅក្នុងសវនាការមេធាវីមិនត្រូវបានអនុញ្ញាតិឱ្យធ្វើការសួរដេញដោលទៅលើសាក្សី ដែលផ្ទុយទៅនឹងមាត្រា ២៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ស្តីពីមធ្យោបាយបង្ហាញភស្តុតាង ថ្វីត្បិតតែចៅក្រមជំនុំជំរះបានសន្យាថា អនុញ្ញាតឱ្យមានការសួរដេញដោលក៏ដោយ ។

៣-ចៅក្រមមិនអនុញ្ញាតិឱ្យសាក្សីដោះបន្ទុកធ្វើការឆ្លើយបំភ្លឺទាល់តែសោះនៅក្នុងសវនាការ ទោះបីជាមេធាវីរបស់ឯកឧត្តម ជាម ច័ន្ទនី បានស្នើសុំបញ្ចូលសាក្សីនៅពេលបើកសវនាការដំបូងក៏ដោយ។

៤-ពុំមានភស្តុតាងយកជាការបាន ដែលថា ឯកឧត្តម ជាម ច័ន្ទនី បានប្រព្រឹត្តិបទល្មើស ។

៥-ចៅក្រមនិងព្រះរាជអាជ្ញាបានអនុញ្ញាតិឱ្យក្រឡាបញ្ជីអាននូវកំណត់ហេតុសាក្សីអវត្តមានជាច្រើន និង ស្លាប់ ដែលមិនអាចឱ្យមេធាវីរបស់ ឯកឧត្តម ជាម ច័ន្ទនី មានឱកាសធ្វើការសាកសួរដេញដោលបាន ដែលនេះជាការបំពានលើសិទ្ធិជនជាប់ចោទ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ក្នុងរឿងក្តីនេះពុំមានភស្តុតាងគ្រប់គ្រាន់នៅក្នុងការចោទប្រកាន់លើឯកឧត្តម ជាម ច័ន្ទនី នោះទេ ។ ថ្វីត្បិត តែការសំរេចដាក់ទោស ឬ មិនដាក់ទោសស្ថិតនៅលើឆន្ទានុសិទ្ធិរបស់ចៅក្រមក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមអំពាវនាវឱ្យចៅក្រមយកពត៌មានទទួលបានមកពីការសួរដេញដោលនាពេលសវនាការមកធ្វើការសំរេចសេចក្តី និង សុំកុំឱ្យមានការពិចារណាលើពត៌មានផ្សេង ដែលទទួលបានក្រោយពេលសវនាការ ។

ភ្នំពេញ, ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

**ពត៌មានបន្ថែមសូមទាក់ទង:**

-លោក **សុក សំអឿន** អ្នកសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និង ជានាយក CDP ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩
-លោកស្រី **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ ទូរស័ព្ទលេខ: ០១២ ៨០២ ៥០៦
-លោក **ធន សារាយ** ប្រធានសមាគមអាដហុក ទូរស័ព្ទលេខ ០១៦ ៨៨០ ៥០៩